# មាគ៌ាឆ្ពោះទៅរកយុត្តិធម៌

# សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្តោតលើ

# ជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច

## សេចក្តីសង្ខេប

ក្រសួងយុត្តិធម៌ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៥

## ក្របខណ្ឌទស្សនទាន

ការសិក្សាស្រាវជ្រាវនេះបានកំណត់និយមន័យនៃ *សិទ្ធិទទួលបានយុត្តិធម៌* ថាជា "*លទ្ធភាពរបស់បុគ្គលម្នាក់ ក្នុងការស្វែងរក និងទទួលបាននូវការឆ្លើយតបមួយប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌ ដើម្បីដោះស្រាយវិវាទ ការពារសិទ្ធិ និងត្រួតពិនិត្យការរំលោភអំណាច តាមរយៈយន្តការមួយប្រកបដោយតម្លាភាព គណនេយ្យភាព និងមានតម្លៃសមរម្យ*"។ យន្តការនេះ ត្រូវតែមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការសង្គម និងយកចិត្តទុកដាក់ ចំពោះបញ្ហា យេនឌ័រ ភាសា និងវប្បធម៌។

ការសិក្សានេះក៏វិភាគលើតម្រូវការយុត្តិធម៌នៅក្នុងសង្គម និងការផ្តល់សេវាកម្មយុត្តិធម៌។ តម្រូវការយុត្តិធម៌ក្នុងសង្គម កើតចេញពីសេចក្តីត្រូវការបីនៅក្នុងសង្គមដែលរួមមាន: ១).ការដោះស្រាយវិវាទ ២).ត្រួតពិនិត្យការរំលោភអំណាច និង ៣).ការការពារសិទ្ធិបុគ្គល និងសិទ្ធិសង្គម។ ដោយសារមានតម្រូវការបែបនេះ ទើបករណីមួយចំនួនអាចជា *ករណីដែលអាចជារឿងក្តីបាន*។ នោះជាករណីទាំងឡាយណា ភាគីអាចប្តឹងទៅជនទីបីដើម្បីរកដំណោះស្រាយ។ ការដោះស្រាយនេះអាចធ្វើឡើងដោយស្របទៅតាមច្បាប់ ឬ តាមទំនៀមទំលាប់ ឬ គោលការណ៍ស្មើភាព ឬ ការចរចារលើផលប្រយោជន៍របស់គូភាគី។ ការផ្តល់សេវាកម្មយុត្តិធម៌គឺធ្វើឡើងដោយភ្នាក់ងារទីបីណាមួយ ដែលភ្នាក់ងារទាំងនោះអាចជាបុគ្គល ស្ថាប័ន ឬជាអង្គការណាមួយ ដើម្បីជួយស្វែងរកដំណោះស្រាយ នៅពេលដែលមានតម្រូវការយុត្តិធម៌ក្នុងសង្គម។ រាល់ការផ្តល់សេវាកម្មយុត្តិធម៌ នេះអាចមានចែងក្នុងច្បាប់ និងករណីខ្លះពុំមានចែងដោយច្បាប់ឡើយ។

ការគោរព និងធានានូវសិទ្ធិទទួលបានយុត្តិធម៌ តម្រូវឱ្យមានស្ថាប័នដែលប្រកបដោយប្រជាធិបតេយ្យ មានអភិបាលកិច្ចល្អ និងមានស្ថាប័នផ្តល់សេវាកម្មយុត្តិធម៌ប្រកបដោយគណនេយ្យភាព។ ទាំងនេះជាមូលដ្ឋាននៃការវាយតម្លៃថាតើការផ្តល់សេវាកម្មយុត្តិធម៌ ពិតជាត្រឹមត្រូវ និងមានការពេញចិត្តពីអ្នកទទួល និងឆ្លើយតបទៅនឹងតម្រូវការយុត្តិធម៌ក្នុងសង្គមស្របតាមនិយាមសិទ្ធិមនុស្សដែរឬយ៉ាងណា។ អនុសាសន៍សម្រាប់ការកែលំអសិទ្ធិទទួលបានយុត្តិធម៌ អាចទទួលយកបានតាមរយៈការសិក្សាវិភាគលើផ្នែកទាំងឡាយដែលបរាជ័យ ឬ ខកខានក្នុងការបំពេញ និងឆ្លើយតបចំពោះតម្រូវការយុត្តិធម៌ក្នុងសង្គម។ ដោយវាជាផ្នែកមួយនៃការធ្វើកំណែទម្រង់តាមបែបប្រជាធិបតេយ្យ ការកែលំអសិទ្ធិទទួលបានយុត្តិធម៌ ទាមទារឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។

## គោលបំណង និងវិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវ

គោលបំណងសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះគឺ (១).កំណត់ និងរកឱ្យឃើញនូវចរិតលក្ខណៈ និងទំហំនៃតម្រូវការយុត្តិធម៌ក្នុងសង្គម (២).វាយតម្លៃទូទៅលើការផ្តល់សេវាកម្មយុត្តិធម៌ (៣).ពង្រឹងដល់ក្រុមគោលដៅ ដោយផ្តល់ព័ត៌មាន និងបង្កើនសមត្ថភាព ដើម្បីឱ្យពួកគេអាចចូលរួមក្នុងដំណើរការពិគ្រោះយោបល់ និង (៤).លើកអនុសាសន៍នានាដោយផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់នេះ ដើម្បីរួមចំណែកកែលំអគោលនយោបាយស្តីពីសិទ្ធិទទួលបានយុត្តិធម៌ ជាពិសេសទាក់ទងទៅនឹងយុត្តិធម៌នៅមូលដ្ឋាន។

ការពិគ្រោះយោបល់ និងការចូលរួម គឺជាវិធីសាស្ត្រស្នូលសម្រាប់ដំណើរការសិក្សាស្រាវជ្រាវនេះ។ ការសិក្សានេះរួមបញ្ចូលទាំងការពិគ្រោះយោបល់ និងទស្សនកិច្ចសិក្សានៅតាមខេត្ត-ក្រុង ចំនួន ៨ ក្នុងចំណោមខេត្ត-ក្រុង ទាំង២៤នៃព្រះរាជាណាចក្រកម្ពុជា។ ឧបករណ៍សំខាន់ៗ ដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សានេះរួមមាន : (ក).ការសិក្សាស្វែងយល់ និងវិភាគព័ត៌មានពាក់ព័ន្ធលើឯកសារដែលមានស្រាប់ (ខ).ការស្ទង់មតិ ដែលបានសាកសួរជាមួយក្រុមគោលដៅប្រមាណ ២.០០០នាក់ នៅក្នុងខេត្តចំនួន ៤ (គ).ធ្វើទស្សនកិច្ចសិក្សានៅខេត្ត-ក្រុង ចំនួន ៨ (ឃ).សម្ភាសន៍ជាមួយមនុស្សយ៉ាងហោចណាស់ ១៥០នាក់ នៅខេត្តចំនួន ៨ នេះផងដែរ (ង).សិក្សានិងវិភាគលើករណីនៃរឿងក្ដីមួយចំនួន ព្រមទាំងសង្កេតមើលការដោះស្រាយវិវាទនៅខេត្ត-ក្រុងចំនួន ៧ (ច).រួមទាំងសិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋានចំនួនបី និងវេទិកាថ្នាក់ជាតិមួយ ដែលមានសមាសភាពចូលរួមសរុបទាំងអស់ប្រមាណជា ៤០០នាក់ ចូលរួមពិគ្រោះយោបល់ និង (ឆ).មានកិច្ចប្រជុំធ្វើការកែសំរួលជាមួយដៃគូស្រាវជ្រាវ និងបន្ទាប់មកមានកិច្ចប្រជុំធ្វើសុពលភាពមួយនៅភ្នំពេញ ដើម្បីផ្ដល់សុពលភាពលើរបាយការណ៍សិក្សានេះ។

លទ្ធផលរកឃើញចម្បងៗ :

**លទ្ធផល-វិវាទជាចម្បងៗ**

វិវាទដែលកើតមានរៀងរាល់ថ្ងៃរវាងអ្នកជិតខាង និងរវាងសមាជិកនៃក្រុមគ្រួសារ ពាក់ព័ន្ធនឹងការងារប្រចាំថ្ងៃរវាងគ្នានិងគ្នា កើតមានជាញឹកញាប់ ដែលជម្លោះទាំងនេះជាទូទៅមិនមានលក្ខណៈធ្ងន់ធ្ងរទេ ហើយត្រូវបានដោះស្រាយនៅថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងនេះក្ដី វិវាទដីធ្លីដែលមានទ្រង់ទ្រាយធំ ដោយភាគីវិវាទមិនមានតុល្យភាពនៃអំណាចក្នុងការចរចារ គឺមានលក្ខណៈខុសប្លែកពីវិវាទតូចតាច។ វិវាទដីធ្លីទាំងនេះអាចជាការបណ្ដេញប្រជាពលរដ្ឋឱ្យចេញពីដី ដោយហេតុផលនៃការធ្វើសម្បទានដល់ក្រុមហ៊ុនវិនិយោគ ឬការចាប់យកដី ដោយក្រុមហ៊ុន ទាហាន មន្ត្រីមានអំណាចថ្នាក់ខ្ពស់ ឬដោយអ្នកមានទ្រព្យសម្បត្តិច្រើន ព្រមទាំងការទន្ទ្រានយកដីរបស់បងប្អូនជនជាតិដើមភាគតិច តាមរយៈអ្នករកស៊ីកំរៃជើងសារ។ វិវាទដីធ្លីបែបនេះ ត្រូវបានចាត់ទុកថាជាបញ្ហាដ៏ធ្ងន់ធ្ងរមួយរបស់ប្រទេសនេះ ហើយមានការលំបាកក្នុងការដោះស្រាយ។ ភាគច្រើននៃវិវាទដីធ្លីទាំងនេះ គឺកំពុងតែរង់ចាំដំណោះស្រាយ ដែលរឿងខ្លះអាចបង្កឱ្យមានបញ្ហាផ្សេងៗទៀត និងខ្លះអាចឈានដល់អំពើហិង្សា។

អំពើហិង្សាក្នុងគ្រួសារជាបញ្ហាមួយដែលធ្ងន់ធ្ងរជាងគេ ហើយកើតមានញឹកញាប់ជាងគេបំផុតផងដែរ នៅក្នុងប្រទេស។ ភាគច្រើននៃអំពើហិង្សាក្នុងគ្រួសារ ការផ្ដាច់សង្វាស ការផ្ដល់អាហារកិច្ច និងរួមទាំងអំពើរំលោភសេពសន្ថវៈ ត្រូវបានដោះស្រាយនៅមូលដ្ឋានដោយប្រើប្រាស់ទំនៀមទំលាប់នៅមូលដ្ឋាន ដោយប្រធានភូមិ ឬអាជ្ញាធរក្រុមប្រឹក្សាឃុំ។ ទោះជាយ៉ាងនេះក្ដី អាជ្ញាធរទាំងនេះ ភាគច្រើនផ្ដោតទៅលើការដោះស្រាយបញ្ចប់ទំនាស់ជូនគូភាគី ជាជាងយកចិត្តទុកដាក់ដល់ការលើកស្ទួយ និងការពារសិទ្ធិរបស់ភាគី។ បញ្ហាបទល្មើសព្រហ្មទណ្ឌដែលប៉ះពាល់ដល់ក្រុមគោលដៅ រួមមាន បទល្មើសតូចតាច បទល្មើសធ្ងន់ធ្ងរមួយចំនួន និងសកម្មភាពបងតូចបងធំនានា។ កង្វះនូវឱកាសទទួលបានការងារ និងការបរិភោគស្រា ក៏ដូចជាការប្រើប្រាស់គ្រឿងញៀនជាប្រភពមួយផងដែរ ក្នុងការនាំឱ្យមានសកម្មភាពបទល្មើសពួកបងតូចបងធំ។ ការរើសអើងប្រឆាំងជនជាតិ ភាគតិច ក៏ជាឥទ្ធិពល ដែលប៉ះពាល់ដល់ក្រុមជនជាតិភាគតិចនានា រួមទាំងជនជាតិដើមភាគតិចផងដែរ។

**លទ្ធផល-ការរំលោភសិទ្ធិ**

ទម្រង់ផ្សេងៗនៃការរំលោភអំណាច ដែលនាំឱ្យមានការរំលោភសិទ្ធិបុគ្គល រាប់បញ្ចូលទាំងការរំលោភអំណាចដោយនគរបាល នៅក្នុងបរិបទនៃការទប់ស្កាត់នៃការតវ៉ារបស់សង្គម។ ការរំលោភនេះ គឺរួមទាំងការរំលោភលើវិធាននីតិវិធីច្បាប់

ដោយនគរបាល មន្ត្រីតុលាការ និងមន្ត្រីពន្ធនាគារ។ ការនេះអាចជាហេតុបណ្តាលឱ្យមានការវាយធ្វើបាបនៅពេលចាប់ខ្លួន ខ្វះនូវមេធាវីជួយការពារពេលសវនាការ ការឃុំខ្លួនបណ្តោះអាសន្នហួសពេលកំណត់ និងស្ថានភាពពន្ធនាគារពុំសមរម្យ។ ការរំលោភសិទ្ធិទាំងនេះ គឺបណ្តាលមកពីការខ្វះខាតធនធានមនុស្ស និងធនធានសំភារៈ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការខ្វះខាតនូវមេធាវី ព្រមទាំងខ្វះនូវគណនេយ្យភាពក្នុងប្រព័ន្ធយុត្តិធម៌ជាទូទៅ។ អំពើពុករលួយក្នុងការផ្តល់សេវាកម្មយុត្តិធម៌ជូនពលរដ្ឋបណ្តាលឱ្យមានភាពលំអៀង និងរំលោភសិទ្ធិបុគ្គល។ អំពើពុករលួយបង្កឱ្យមានការប៉ះពាល់គ្រប់បែបយ៉ាងទាំងអស់ក្នុងគោលគំនិត *ស្តីអំពីយុត្តិធម៌* ដោយសារថា ដំណោះស្រាយគឺវាអាស្រ័យលើការប្រើលុយកាក់ និងអំណាចរបស់គូភាគី។

### លទ្ធផល-អំពើពុករលួយ

ទម្រង់នៃអំពើពុករលួយដែលប៉ះពាល់ដល់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានសាធារណៈប្រកបដោយអំពើពុករលួយ និងខ្វះតម្លាភាព ដូចជាការផ្តល់ដីសម្បទាន ការគ្រប់គ្រងធនធានធម្មជាតិ ការអនុញ្ញាតច្បាប់ធ្វើអាជីវកម្ម ការធ្វើលទ្ធកម្មក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសេចក្តីសម្រេចនយោបាយផ្សេងៗទៀត ទាក់ទិននឹងទ្រព្យសម្បត្តិសាធារណៈ សេវាសាធារណៈ និងការបង់ពន្ធជាដើម។

ប្រាក់ខែទាបជាមូលហេតុមួយដែលបានលើកឡើង និងនាំឱ្យមានការតម្រូវឱ្យបង់ប្រាក់ឈ្នួលខុសច្បាប់ពីសំណាក់គ្រូបង្រៀន ពេទ្យ និងមន្ត្រីសាធារណៈ ជាថ្នូរនឹងការផ្តល់សេវាសាធារណៈ។ ពេលខ្លះការដែលតម្រូវឱ្យបង់ប្រាក់ដោយខុសច្បាប់បែបនេះ នាំឱ្យក្មេងៗមិនអាចចូលសាលាបាន អ្នកក្រីក្រមិនអាចទទួលបានសេវាសុខភាព និងជនរងគ្រោះនៃបទល្មើសផ្សេងៗ មិនអាចទទួលបាននូវការធ្វើកោសល្យវិច្ច័យបាន។ មន្ត្រីរាជការជាញឹកញាប់យល់ថា មុខងារក្នុងសេវាសាធារណៈ ជាប្រភពដើម្បីរកចំណូលបន្ថែមលើប្រាក់ខែដែលខ្លួនត្រូវទទួល។ មនុស្សជាច្រើនបានចាត់ទុកអំពើពុករលួយបែបនេះថាជាផ្នែកមួយនៃភាពក្រីក្រ។ តែពួកគេមិនបានចាត់ទុកថា អំពើពុករលួយនេះជាការរំលោភលើសិទ្ធិសង្គមរបស់ពួកគេ ហើយពួកគេក៏មិនដឹងថា នេះជាសិទ្ធិស្របច្បាប់ ដែលគេអាចទាមទារបានតាមផ្លូវច្បាប់។

### លទ្ធផល-ការផ្តល់សេវាកម្មយុត្តិធម៌

នៅថ្នាក់ភូមិ មានប្រធានភូមិ និងចាស់ទុំ ជាអ្នកទទួល និងជួយដោះស្រាយភាគច្រើននៃវិវាទដែលកើតមាននៅក្នុងភូមិនីមួយៗ។ ក្រុមប្រឹក្សាឃុំដោះស្រាយជូនប្រជាពលរដ្ឋនូវវិវាទផ្សេងៗជាច្រើនប្រភេទ។ វិវាទទាំងនេះអាចរួមបញ្ចូលទាំងជម្លោះដែលកើតមានញឹកញាប់នៅមូលដ្ឋាន ដូចជាជម្លោះរវាងសមាជិកគ្រួសារអ្នកជិតខាង វិវាទដីធ្លី វិវាទទាក់ទងនឹងអំពើហិង្សាខាងយេនឌ័រ ដូចជា អំពើហិង្សាក្នុងគ្រួសារ និងការលែងលះបណ្តាលមកពីអំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភផ្លូវភេទ និងករណីព្រហ្មទណ្ឌនានា។ ជាមធ្យម ឃុំនីមួយៗដោះស្រាយរឿងក្តីបានប្រមាណជា ២៥ករណី ក្នុង ១ឆ្នាំ។ នៅទូទាំងប្រទេសកម្ពុជាមានឃុំ-សង្កាត់ សរុបចំនួន ១៦២១ ឃុំ-សង្កាត់ ហេតុនេះបើយើងសរុបទៅគឺក្នុង១ឆ្នាំៗ មានរឿងក្តីប្រមាណប្រហែលជា ៤០.០០០ករណី ដែលត្រូវបានដោះស្រាយនៅថ្នាក់ឃុំ នៅទូទាំងប្រទេស។ ភាគច្រើនក្រុមប្រឹក្សាឃុំដោះស្រាយវិវាទជូនប្រជាពលរដ្ឋតាមការសម្រុះសម្រួល។ សម្រាប់ករណីដែលមានគូភាគី មានតុល្យភាពនៃឋានៈក្នុងសង្គម និងទ្រព្យសម្បត្តិនោះមានភាពងាយស្រួល ក្នុងការដោះស្រាយ តែមានការលំបាកដោះស្រាយសម្រាប់ករណី ដែលភាគីម្ខាងជាអ្នកមានអំណាច។ ករណីភាគច្រើន ដែលសម្រុះសម្រួលដោយក្រុមប្រឹក្សាឃុំ តាមច្បាប់គួរតែត្រូវបានដោះស្រាយដោយតុលាការ តែប្រជាពលរដ្ឋចូលចិត្តប្តឹងទៅអាជ្ញាធរមូលដ្ឋាន ជាជាងតុលាការ ដោយមូលហេតុថា ប្រជាពលរដ្ឋមានលក្ខណៈងាយស្រួលក្នុងការចូលទៅរកជំនួយពីអាជ្ញាធរមូលដ្ឋាន ព្រោះនៅជិតផ្ទះ ចំណាយតិច គូភាគីអាចមានឱកាសចរចារគ្នាដោយផ្ទាល់ និងពួកគាត់យល់ច្បាស់ពីនីតិវិធីនៅមូលដ្ឋាន។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅតែមានការតវ៉ាមួយចំនួនប្រឆាំងនឹង ក្រុមប្រឹក្សាឃុំទាក់ទងនឹង :

ភាពលំអៀង តម្លៃ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ដែលខ្វះការយល់ដឹងពីច្បាប់ និងខ្វះការទទួលខុសត្រូវ (គណនេយ្យភាព)។

អភិបាលស្រុក ក្នុងនាមជានគរបាលយុត្តិធម៌ មានតួនាទីជាអ្នកសម្រុះសម្រួលផងដែរ។ នាពេលបច្ចុប្បន្ននេះ ការត្រួតពិនិត្យនិងតុល្យភាពអំណាចលើមុខងារទាំងនេះ មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ គូភាគីខ្លះប្ដឹងទៅថ្នាក់ស្រុក បើសិនជារឿងក្ដីរបស់ខ្លួនមិនអាចដោះស្រាយបាននៅថ្នាក់ឃុំ។ តែអាជ្ញាធរថ្នាក់ស្រុកពុំមានសមត្ថកិច្ចស្របច្បាប់ ដើម្បីដោះស្រាយវិវាទដោយធ្វើសេចក្ដីសម្រេចឡើយ។ អភិបាលខេត្តជាប្រធាននៃគណៈកម្មការសុរិយោដីខេត្ត ដែលមានភារៈដោះស្រាយវិវាទដីធ្លី។ បច្ចុប្បន្ននេះ ប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាច លើមុខងារទាំងនេះក៏មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ នគរបាលនៅថ្នាក់ឃុំ និងថ្នាក់ស្រុក ទទួលរឿងក្ដីព្រហ្មទណ្ឌ តែច្បាប់មិនអនុញ្ញាតឱ្យនគរបាលនៅថ្នាក់ឃុំ និងថ្នាក់ស្រុក មានសិទ្ធិបញ្ជូនរឿងក្ដីព្រហ្មទណ្ឌទៅព្រះរាជអាជ្ញាដោយផ្ទាល់ទេ គឺគ្រប់រឿងក្ដីព្រហ្មទណ្ឌត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាតាមរយៈនគរបាលនៅថ្នាក់ខេត្ត។ យោងតាមយោបល់របស់អ្នកចូលរួមសិក្ខាសាលា ការដែលធ្វើដូចនេះ គឺអនុញ្ញាតឱ្យមានឱកាស ៣ដង (ដល់នគរបាលថ្នាក់ឃុំ ស្រុក និងខេត្ត) ដើម្បីធ្វើការសម្រុះសម្រួលក្រៅផ្លូវការ រវាងជនរងគ្រោះនិងជនល្មើស ក្នុងការចរចាដើម្បីបញ្ចប់រឿងក្ដី ទៅចំពោះមុខនគរបាល។ បន្ថែមលើនេះ នគរបាលក៏ទទួល និងសម្រុះសម្រួលរឿងក្ដីរដ្ឋប្បវេណីមួយចំនួនផងដែរ។ ការដែលធ្វើការសម្រុះសម្រួលក្រៅផ្លូវការបែបនេះ ជនល្មើសអាចគេចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ហើយជនរងគ្រោះអាចទទួលបាននូវសំណងខូចខាតខ្លះ ដែលជនរងគ្រោះប្រហែលជាមិនអាចទទួលបានឡើយ បើសិនជារឿងក្ដីនោះត្រូវបានដោះស្រាយតាមផ្លូវតុលាការ។ ដោយសារតែមានការអនុវត្តបែបនេះ គឺវាបង្ហាញពីភាពចាំបាច់ឱ្យមានការត្រួតពិនិត្យយុត្តាធិការចំពោះនគរបាលនៅមូលដ្ឋាន និងអំពីភាពចាំបាច់ឱ្យមានគោលការណ៍ ស្ដីពីការបង់ប្រាក់សំណងការខូចខាតច្បាស់លាស់ដល់ជនរងគ្រោះ ប្រសើរជាងប្រាក់សំណង ដែលផ្ដល់ដោយតុលាការ ។

តុលាការ និងការិយាល័យអយ្យការ មានតែនៅក្នុងទីរួមខេត្ត-ក្រុងប៉ុណ្ណោះ នៅពេលដែលប្រជាពលរដ្ឋប្រមាណជា ៨០% រស់នៅជនបទដាច់ស្រយាល។ តុលាការដោះស្រាយរឿងក្ដីប្រមាណជា ១២.០៤៣ ករណីក្នុងឆ្នាំ២០០៣។ នៅក្នុងនោះរឿងក្ដីរដ្ឋប្បវេណីដែលប្ដឹងទៅតុលាការប្រហែលជាពាក់កណ្ដាលជារឿងពាក់ព័ន្ធនឹងការលែងលះ ក្នុងរឿងលែងលះទាំងនោះមានប្រហែលជា ៨០% នៃរឿងលែងលះ គឺប្ដឹងដោយភាគីស្ត្រី។ យោងតាមចៅក្រមដែលក្រុមសិក្សាស្រាវជ្រាវបានជួបសម្ភាសន៍បានឱ្យដឹងថា រឿងក្ដីលែងលះភាគច្រើន គឺបណ្ដាលមកពីអំពើហិង្សាក្នុងគ្រួសារ និងខ្វះទំនួលខុសត្រូវរបស់ប្ដីចំពោះគ្រួសារ និងកូន។ ក្នុងករណីមានបទល្មើសរំលោភសេពសន្ថវៈ ឬបង្ករបួសស្នាមបណ្ដាលមកពីអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះត្រូវតែទៅឱ្យពេទ្យពិនិត្យធ្វើកោសល្យវិច្ច័យ ដើម្បីយកជាភស្តុតាងសម្រាប់ឱ្យព្រះរាជអាជ្ញាចាត់ការ និងអាចបញ្ជូនរឿងក្ដីទៅចៅក្រម។ ជនរងគ្រោះក្នុងករណីនេះ ត្រូវតែបង់ប្រាក់សម្រាប់ការធ្វើកោសល្យវិច្ច័យ។

ចាប់តាំងពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៤ គណៈកម្មការសុរិយោដីបានទទួល រឿងក្ដីដីធ្លីច្រើនជាង ២០០០ករណីហើយ។ រហូតមកដល់ដើមឆ្នាំ២០០៥ នេះ គឺមានរឿងក្ដីតែ ២៦% ប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយនៅពេលដែលមានរឿងក្ដីប្រមាណជា ១០% ត្រូវបានបដិសេធចោល ហើយនិងប្រហែល ២ ភាគ ៣ នៅមិនទាន់ដោះស្រាយនៅឡើយ។ គណៈកម្មការសុរិយោដី គឺជាផ្នែកមួយនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលមានការិយាល័យធ្វើការនៅថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ ហើយនៅតែមានការខ្វះខាតខាងធនធានមនុស្ស និងធនធានសំភារៈនៅឡើយ។ គណៈកម្មការនេះ មានប្រសិទ្ធិភាពច្រើននៅពេលដោះស្រាយវិវាទ ដីធ្លីរវាងអ្នកភូមិនិងអ្នកភូមិ។ តែមិនសូវមានប្រសិទ្ធិភាពទេ បើវិវាទកើតមានពាក់ព័ន្ធនឹងដីធ្លីមានទ្រង់ទ្រាយធំ ដែលភាគីម្ខាងជាអ្នកមានអំណាច។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ មិនទាន់បានចេញសេចក្ដីសម្រេចណាមួយនៅឡើយទេ គិតចាប់តាំងពីការបង្កើតមកដល់ខែកក្កដា ឆ្នាំ២០០៥ នេះ។ ក្នុងច្បាប់ពាក់ព័ន្ធពុំមាន "ខ" ចែងណាមួយ

ដែលកំណត់អំពីពេលវេលា ដែលត្រូវប្រើដើម្បីដោះស្រាយ និងសម្រេចឱ្យបានចំពោះវិវាទ ដែលគណៈកម្មការនេះបានទទួលឡើយ។ លើសពីនេះទៅទៀត នៅខេត្តដែលមានជនជាតិដើមភាគតិច ភាគច្រើនរស់នៅ គណៈកម្មការនេះធ្វើការមិនសូវមានប្រសិទ្ធិភាពទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយវិវាទការងារ ចាប់តាំងពីខែឧសភា ឆ្នាំ២០០៣ មកដល់ខែមិថុនា ឆ្នាំ២០០៥ បានទទួលដោះស្រាយរឿងក្ដីបានចំនួន ១៨២ ករណីហើយ។ រឿងក្ដីដែលបានទទួលចំនួន ២ ភាគ ៣ នៃវិវាទដែលបានទទួល គឺត្រូវបានដោះស្រាយជូនភាគីវិវាទ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមាននីតិវិធី និងការកំណត់ពេលវេលាយ៉ាងច្បាស់លាស់។ ក្រុមប្រឹក្សានេះទទួលការឧបត្ថម្ភពីអង្គការពលកម្មអន្តរជាតិ។ សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាល (មជ្ឈតករ) ទាំងអស់ជាមនុស្សឯករាជ្យ បានទទួលការបណ្ដុះបណ្ដាលជំនាញត្រឹមត្រូវ មានការទទួលស្គាល់នៅក្នុងសហគមន៍អ្នកច្បាប់។ ក្នុងចំណោមនិយោជិតទាំងអស់ដែលក្រុមសិក្សាស្រាវជ្រាវបានសម្ភាសន៍ គ្មានអ្នកណាម្នាក់រិះគន់ថាមានអំពើពុករលួយ នៅក្នុងក្រុមប្រឹក្សានេះឡើយ។ បញ្ហាគឺថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មានតែការិយាល័យមួយប៉ុណ្ណោះ ដែលមានទីតាំងនៅ ទីក្រុងភ្នំពេញ។ លើសពីនេះទៀត ក៏មានការបារម្ភផងដែរ អំពីនិរន្តរភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បើសិនជាអង្គការពលកម្ម អន្តរជាតិបញ្ឈប់ការឧបត្ថម្ភរបស់ខ្លួន។

សម្រាប់សហគមន៍ជនជាតិដើមភាគតិច ចាស់ទុំជាអ្នកជួយដោះស្រាយ រាល់វិវាទកើតមាននៅក្នុងសហគមន៍។ ជនជាតិដើមភាគតិច ដែលបានចូលរួមក្នុងសិក្ខាសាលា បានសំណូមពរឱ្យមានការទទួលស្គាល់ចំពោះអាជ្ញាធរប្រពៃណីរបស់ពួកគេ ហើយនិងទទួលស្គាល់យន្តការដោះស្រាយវិវាទរបស់ពួកគេ។ បញ្ហាចម្បង១ ដែលបងប្អូនជនជាតិដើមភាគតិចប្រឈមជាមួយអ្នកខាងក្រៅសហគមន៍របស់ពួកគេ គឺការដកយកកម្មសិទ្ធិដីធ្លី ដែលជាដីរួមរបស់សហគមន៍ ដោយសារតែពុំមានការកំណត់ព្រំដីច្បាស់លាស់ និងពុំមានប័ណ្ណកម្មសិទ្ធិលើដីធ្លី។ គណៈកម្មការសុរិយោដី មិនសូវមានប្រសិទ្ធិភាពទេនៅក្នុងបណ្ដាខេត្តដែលមានជនជាតិដើមភាគតិចច្រើនរស់នៅ។ បញ្ហាមួយទៀត គឺអំពីកង្វះខាតនូវជំនួយផ្នែកច្បាប់ និងអ្នកបកប្រែភាសាសម្រាប់ជនជាតិដើមភាគតិច នៅពេលដែលមានសមាជិកជនជាតិដើមភាគតិច ត្រូវប្រឈមនឹងនីតិវិធីច្បាប់ នៅក្នុងចំណាត់ការក្ដីតាមផ្លូវតុលាការ។

អនុសាសន៍

**បង្កើតសេវាយុត្តិធម៌ទៅជិតជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច**

- ពង្រឹង និងកែលំអយន្តការដោះស្រាយវិវាទនៅតាមមូលដ្ឋាន ដែលយន្តការនោះជួយដោះស្រាយវិវាទ តាមរយៈការផ្សះផ្សា ការសម្រុះសម្រួល និងតាមរូបភាពជាមជ្ឈតវិនិច្ឆ័យ (អាជ្ញាកណ្ដាល) នៅថ្នាក់ភូមិ និងឃុំ ដោយផ្ដល់ការបណ្ដុះបណ្ដាល ដល់ពួកគេអំពីយន្តការដោះស្រាយវិវាទក្រៅតុលាការ សិទ្ធិមនុស្ស និងច្បាប់ពាក់ព័ន្ធដទៃៗទៀត (ច្បាប់ភូមិបាល អំពើហិង្សាក្នុងគ្រួសារជាដើម ។ល។)
- ត្រូវផ្ដល់អំណាចយុត្តាធិការដល់អាជ្ញាធរថ្នាក់ស្រុក ឱ្យមានសិទ្ធិសម្រេចលើរឿងក្ដីរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌតូចតាច។ អាជ្ញាធរនេះគួរតែសម្រេចសេចក្ដីដោយអនុវត្តទំនៀមទំលាប់ប្រពៃណីនៅមូលដ្ឋាន និងអាចការពារសិទ្ធិដល់ភាគីផងដែរ។ ស្ថាប័ននេះផងដែរ គួរតែមានសមត្ថកិច្ច ឬយុត្តាធិការផងដែរក្នុងការដោះស្រាយវិវាទទាក់ទិននឹងអំពើហិង្សាក្នុងគ្រួសារ វិវាទរវាងប្ដី-ប្រពន្ធ ដែលរៀបការតាមប្រពៃណី តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់តម្រូវ នៅពេលដែលពួកគេមានបញ្ហាចង់លែងលះ ឬបែងចែកទ្រព្យសម្បត្តិរួម។ អាជ្ញាធរនេះ គួរតែជាក្រុមប្រឹក្សាដែលមានសមាជិក ៣ (បី) រូប ហើយក្នុងនោះយ៉ាងហោចណាស់ម្នាក់ជាស្ត្រី និងទទួលបានការបណ្ដុះបណ្ដាលសមរម្យ។

• ទទួលស្គាល់ និងពង្រឹងច្បាប់ជនជាតិដើមភាគតិច និងយន្តការដោះស្រាយវិវាទ ដែលកើតមាននៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងវិវាទរវាងជនជាតិដើមភាគតិចជាមួយអ្នកខាងក្រៅ តាមរយៈការពិគ្រោះយោបល់ជាមួយពួកគេ។ បង្កើតឱ្យមានយន្តការមួយដើម្បីកែលំអ និងជួយពង្រឹងអាជ្ញាធរ ជនជាតិដើមភាគតិច ឱ្យមានតម្លាភាព និងការទទួលស្គាល់ទុកចិត្តពីសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាដើរតួក្នុងការសម្របសម្រួលជាមួយស្ថាប័នរដ្ឋាភិបាល និងតុលាការជាដើម។

**កែលំអយន្តការដោះស្រាយវិវាទក្រៅតុលាការផ្សេងៗ**

• បន្ទាប់ពីដំណើរការពិគ្រោះយោបល់ ត្រូវអនុម័តច្បាប់ស្តីពីយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR) ដែលទទួលស្គាល់ទម្រង់ផ្សេងៗនៃ ADR នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងចែងផងដែរថាតើតុលាការអាចបង្ខំឱ្យភាគីអនុវត្ត ឬពិនិត្យឡើងវិញ នូវរាល់សេចក្តីបង្គាប់ និងសេចក្តីសម្រេចរបស់ ADR បានឬយ៉ាងណា។

• បង្កើនសមត្ថភាពគណៈកម្មការសុរិយោដី ដើម្បីដោះស្រាយវិវាទ នៅពេលដែលភាគីវិវាទ មិនមានតុល្យភាពអំណាចចរចាររវាងគ្នានិងគ្នា។ បង្កើតឱ្យមានរយៈពេលកំណត់ច្បាស់លាស់ សម្រាប់តម្រូវឱ្យគណៈកម្មការសុរិយោដីត្រូវដោះស្រាយឱ្យបាន ក្នុងរយៈពេលណាមួយកំណត់នោះ។ អនុក្រឹត្យទាំងឡាយដែលមិនទាន់បានអនុម័តទាក់ទងនឹងដីសម្បទានសេដ្ឋកិច្ច និងការកំណត់ព្រំដីសហគមន៍ជនជាតិដើមភាគតិច គួរតែអនុម័តឱ្យបានឆាប់និងជម្រុញល្បឿននៃការកំណត់ព្រំដី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។

• កែលំអនិងបង្កើនការចូលយកសេវាកម្មយុត្តិធម៌ តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារឱ្យកាន់តែងាយស្រួល ដោយបង្កើតការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅកន្លែងផ្សេងៗទៀតក្រៅក្រុងភ្នំពេញ។ បង្កើនការយល់ដឹងសិទ្ធិនិយោជន៍ (សិទ្ធិខាងពលកម្ម ឬការងារ) របស់និយោជិត ដែលបំរើការងារនៅក្នុងវិស័យកសិ-ឧស្សាហកម្មផ្សេងៗ រួមទាំងចំការកៅស៊ូ ចំការស្វាយចាន់ទី និងចំការដទៃៗទៀត។

**កែលំអប្រព័ន្ធតុលាការកាន់តែឆ្លើយតបទៅនឹងតម្រូវការសង្គម**

• អនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ យកចិត្តទុកដាក់ដល់តម្រូវការ និងសិទ្ធិរបស់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងការរំលោភខាងផ្លូវភេទ។ ធានាដល់ការផ្តល់ប្រាក់សំណងជូនដល់ជនរងគ្រោះ និងមិនត្រូវឱ្យមានប្រាក់ប្រដាប់ក្តីសម្រាប់ករណីបណ្តឹងទាមទារអាហារកិច្ចឡើយ។

• បញ្ចូល និងអនុញ្ញាតឱ្យមានគោលការណ៍នៃការផ្តល់ឱកាសក្នុងការចរចារដើម្បីសម្រាលទោស (plea- bargaining) និងការចែងពិសេសសម្រាប់បទល្មើសតូចតាច។ ច្បាប់គួរអនុញ្ញាតឱ្យជនល្មើសក្នុងរឿងព្រហ្មទណ្ឌ ដែលប្រព្រឹត្តិបទល្មើសតូចតាច ឬរួមចំណែកតិចតួច អាចបង់ប្រាក់សំណងជួសជុលការខូចខាត ជូនដល់ជនរងគ្រោះ ដោយមានការត្រួតពិនិត្យពីអាជ្ញាធរ មានយុត្តាធិការ ដើម្បីចៀសវាងចំណាត់ការក្តីតាមនីតិវិធីតុលាការ។ ដាក់ឱ្យមានវិធានការជំនួសពន្ធនាគារ (Alternatives to prison) ដោយចែងក្នុងច្បាប់ព្រហ្មទណ្ឌ ដូចជាតម្រូវឱ្យធ្វើការងារសហគមន៍។ គួរមានវិធានការកាត់បន្ថយរយៈពេលជាប់ពន្ធនាគារ សម្រាប់ជនទាំងឡាយណា ដែលខិតខំធ្វើការ និងរៀនសូត្រនៅក្នុងពន្ធនាគារ។ បង្កើតឱ្យមានប្រព័ន្ធដោយឡែក សម្រាប់យុត្តិធម៌អនីតិជន។

• ពង្រឹងសមត្ថភាពជំនាញ និងឯករាជ្យភាពរបស់តុលាការ ដើម្បីដោះស្រាយរឿងព្រហ្មទណ្ឌធ្ងន់ធ្ងរ រឿងរដ្ឋប្បវេណីមួយចំនួន ការពារសិទ្ធិមនុស្ស និងត្រួតពិនិត្យការរំលោភអំណាចទាំងឡាយ ដែលអាចកើតឡើងដោយអង្គការនីតិប្រតិបត្តិ ព្រមទាំងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាទូទៅ។

### ពង្រឹងសេវាច្បាប់ និងសេវាកម្មយុត្តិធម៌

- ពង្រឹងការផ្តល់ជំនួយផ្នែកច្បាប់ ជាពិសេសសម្រាប់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។ រៀបចំឱ្យមានកញ្ចប់ថវិកា សម្រាប់គាំទ្រដល់ការបង្កើតការិយាល័យជំនួយការផ្នែកច្បាប់ ជាពិសេសសម្រាប់ប្រជាពលរដ្ឋរស់នៅតំបន់ជនបទដាច់ស្រយាល។ បង្កើនតម្លាភាព បញ្ចូលសមាជិកគណៈមេធាវីថ្មី។
- ធានាឱ្យមានអ្នកបកប្រែសម្រាប់ជនជាតិដើមភាគតិច ជាភាសាដែលពួកគេអាចយល់បាន នៅពេលដែលពួកគេប្រឈមនឹងដំណើរការក្តីតាមផ្លូវច្បាប់ ជាពិសេសក្នុងករណីព្រហ្មទណ្ឌ និងការទាមទារដីធ្លីជាដើម។
- ធានាកុំឱ្យមានការទាមទារតម្លៃធ្វើកោសល្យវិច្ច័យ ពីជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ ដោយរៀបចំឱ្យមានការសម្របសម្រួលសមស្របមួយជាមួយមន្ទីរពេទ្យ ឬរៀបចំឱ្យមានកញ្ចប់ថវិកាសម្រាប់ការងារនេះ។

### បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ដើម្បីរួមចំណែកកែលំអសិទ្ធិទទួលបានយុត្តិធម៌

- ផ្តល់អំណាចដល់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច តាមរយៈការបង្កើនការយល់ដឹងពីសិទ្ធិ និងច្បាប់ដល់ពួកគេ ព្រមទាំងបង្កើនសមត្ថភាព ដើម្បីជាប្រយោជន៍ដល់ការចូលរួម។ ធានាដល់ការចូលរួមរបស់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ដើម្បីឱ្យពួកគេអាចលើកឡើងនូវអ្វីដែលជាតម្រូវការ របស់ពួកគេ ក៏ដូចជាលើកជាសំណូមពររបស់ពួកគេ ចំពោះស្ថាប័នផ្សេងៗដោយផ្ទាល់ ក្នុងគោលបំណងកែលំអសិទ្ធិទទួលបានយុត្តិធម៌របស់ពួកគេ។
- បង្កើតឱ្យមានយន្តការមួយជាក់លាក់ ដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាកម្មយុត្តិធម៌។
- លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួម និងសហប្រតិបត្តិការល្អរវាងស្ថាប័ននានា ដើម្បីជាប្រយោជន៍ ដល់ការកែលំអសិទ្ធិទទួលបានយុត្តិធម៌ នៅគ្រប់លំដាប់ថ្នាក់ (ទាំងថ្នាក់មូលដ្ឋាន ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ)។
- ពង្រឹងភាពជាអ្នកដឹកនាំក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ លើកទឹកចិត្តឱ្យមានការបង្កើនសមត្ថភាព និងការអប់រំបន្ត ក៏ដូចជាការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស យន្តការដោះស្រាយវិវាទ សិទ្ធិស្ត្រី និងសិទ្ធិរបស់ជនជាតិដើមភាគតិច ចំពោះអ្នក ដែលមានការពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មយុត្តិធម៌ រួមទាំងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី អ្នកបកប្រែសម្រាប់ជនជាតិដើមភាគតិច អ្នកធ្វើកោសល្យវិច្ច័យ និងនគរបាលផងដែរ។

# សេចក្តីផ្តើម

"*យុត្តិធម៌សម្រាប់ទាំងអស់គ្នា*" គឺជាគោលដៅចម្បងមួយនៃការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ វាក៏ជាផ្នែកមួយនៃដំណើរការធ្វើកំណែទម្រង់ដ៏ទូលាយ ពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ កំណែទម្រង់រដ្ឋ ការកសាងសន្តិភាព និងប្រជាធិបតេយ្យ ភាវូបនីយកម្មនៅព្រះរាជាណាចក្រកម្ពុជា។ អ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជានាពេលបច្ចុប្បន្ន បានចាប់ផ្តើមចេញពីការសន្មតជាក់លាក់នានា ជុំវិញវិសាលភាព និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ។ ការសន្មតទាំងនោះអាចមានលក្ខណៈជាក់ស្តែង អាចជាការពិពណ៌នា និងអាចជាគោលគំនិត និងជាអ្វីដែលមានចែងជាបទបញ្ញត្តិ។

សេចក្តីសន្និដ្ឋាននានាជុំវិញយុត្តិធម៌មូលដ្ឋាន និងយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)

ការសន្មតទី១ គឺថាជនក្រីក្រ និងក្រុមជនទន់ខ្សោយដែលងាយរងគ្រោះ ប្រឈមនឹងឧបសគ្គជាច្រើន ក្នុងការទទួលយកសេវាយុត្តិធម៌ពីប្រព័ន្ធតុលាការ ដែលឧបសគ្គទាំងនោះរួមទាំងបញ្ហាខាងភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងខាងវប្បធម៌ (តុលាការមានទីតាំងនៅឆ្ងាយ ចំណាយលុយច្រើន និងពិបាកយល់ពីនីតិវិធី)។ ការសន្មតទី២ គឺថាតុលាការមានរឿងក្តីយ៉ាងច្រើនដែលនៅសល់ចាត់ការមិនទាន់ ខ្វះខាតនូវធនធានមនុស្ស និងធនធានសម្ភារៈ ហើយស្ថានភាពនេះនឹងត្រូវការពេលវេលាយ៉ាងយូរដើម្បីធ្វើឱ្យប្រសើរឡើង។ ការសន្មតទី៣ គឺថាក្នុងការអនុវត្តជាក់ស្តែង តុលាការពុំបានដោះស្រាយគ្រប់ប្រភេទរឿងក្តីទាំងអស់ដែលកើតមាននៅក្នុងសង្គមឡើយ ព្រោះមានរឿងក្តីជាច្រើនត្រូវបានគូភាគី ព្យាយាមដោះស្រាយនៅក្រៅតុលាការ តាមរយៈយន្តការដោះស្រាយវិវាទក្រៅផ្លូវការ និងតាមប្រពៃណី ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល។ ជាទំលាប់ប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទដាច់ស្រយាល ព្យាយាមដោះស្រាយវិវាទរបស់ពួកគេតាមយន្តការប្រពៃណី និងតាមវប្បធម៌នៅមូលដ្ឋានរបស់ពួកគេ។ ការសន្មតមានលក្ខណៈជាការពិពណ៌នាខ្លះ មានលក្ខណៈស្របគ្នាជាមួយនឹងការសន្មតដែលមានចែងជាបទបញ្ញត្តិ។ ការសន្មតទី៤ គឺថាជាការមួយល្អប្រសើរ បើសិនជាវិវាទដែលកើតមាននៅក្នុងសង្គមទាំងឡាយ ត្រូវបានដោះស្រាយដោយសន្តិភាព ដោយប្រើប្រាស់នីតិវិធី ដែលអាចឱ្យភាគីទាំងសងខាងឈ្នះ ជាជាងដូចអ្វីដែលតុលាការសម្រេចដែលចាំបាច់ត្រូវមានភាគីអ្នកឈ្នះ និងមានភាគីអ្នកចាញ់នោះឡើយ។ ក្នុងន័យនេះ អ្នកពាក់ព័ន្ធទាំងឡាយជឿថា វាជាការមួយល្អប្រសើរ ដែលតុលាការមិនគ្របដណ្តប់លើគ្រប់ករណី ឬរឿងក្តីទាំងអស់ ដែលកើតមាននៅក្នុងសង្គម តែបង្កើតឱ្យមានស្ថាប័នយន្តការដោះស្រាយវិវាទក្រៅតុលាការ ជួយរួមចំណែកក្នុងការដោះស្រាយវិវាទ។ ជាចុងក្រោយ ការសន្មតទី៥ និងអាចជាការសន្មតដែលមានចែងជាបញ្ញត្តិភាព គឺថាវាជាការមួយល្អប្រសើរ និងចាំបាច់ក្នុងការរកឱ្យឃើញនូវយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន សម្រាប់ដោះស្រាយរាល់វិវាទដែលកើតមាននៅក្នុងសហគមន៍មូលដ្ឋាន។ ដូច្នេះជាផ្នែកមួយនៃដំណើរការនៃការធ្វើវិមជ្ឈការយន្តការដោះស្រាយវិវាទដែលមាននៅមូលដ្ឋាន គួរតែត្រូវបានគេពង្រឹង ដើម្បីជួយដោះស្រាយរាល់បញ្ហាកើតមាននៅមូលដ្ឋាន។ វាក៏ជាការមួយប្រកបដោយគតិបណ្ឌិតរួមផងដែរ បើសិនជាមានរឿងក្តីកាន់តែច្រើនត្រូវបានដោះស្រាយតាមយន្តការដោះស្រាយវិវាទក្រៅតុលាការ ព្រោះវាអាចជួយបន្ថយនូវបន្ទុកជាច្រើនដល់តុលាការ។ ជាក់ស្តែង មានដៃគូផ្តល់ជំនួយមួយចំនួន បានស្នើឱ្យបង្វែរការយកចិត្តទុកដាក់ទៅលើការបង្កើត កែលំអ និងពង្រឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)។

យោងតាមការសន្មតទាំងនេះ ដៃគូពាក់ព័ន្ធនឹងកំណែទម្រង់យុត្តិធម៌ បានសំដែងនូវទស្សនៈរបស់គេថា ចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR) ដែលជាគោលដៅយុទ្ធសាស្ត្រទី៦ នៃ "យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" (LJRS) ព្រាងដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ

យុត្តិធម៌ (CJR) និងអនុម័តដោយគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៣។ ដូចនេះលទ្ធផលរំពឹងទុកមួយនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីផលិតចេញជាការវាយតម្លៃលើយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR) ដែលកំពុងតែដំណើរការនាពេលបច្ចុប្បន្ន (យន្តការដោះស្រាយវិវាទក្រៅតុលាការ ដែលកំណត់ដោយច្បាប់ និងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ឬតាមប្រពៃណី) ហើយនិងវាយតម្លៃលើភាពប្រទាក់ក្រឡាគ្នារវាងយន្តការដោះស្រាយវិវាទផ្លូវការ និងក្រៅផ្លូវការ។ លទ្ធផលរំពឹងទុកមួយផ្សេងទៀត គឺការប្រមូលយកនូវរាល់អនុសាសន៍ និងសំណូមពរទាំងឡាយ ដើម្បីពង្រឹងស្ថាប័ន និងយន្តការដោះស្រាយវិវាទនានា ដែលកំពុងតែអនុវត្តនៅថ្នាក់មូលដ្ឋាន ហើយមិនមែនជាប្រព័ន្ធយុត្តិធម៌ផ្លូវការឡើយ។

តារាងទី១. ការសន្មតនានាទាក់ទងនឹងយុត្តិធម៌មូលដ្ឋាន និងយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)

| អង្គហេតុជាក់ស្តែង | គោលការណ៍ | សំណូមពរ |
|---|---|---|
| ១. មានឧបសគ្គខាងសេដ្ឋកិច្ច វប្បធម៌សង្គម និងនៅឆ្ងាយសម្រាប់ជនក្រីក្រ ដើម្បីរកសេវាយុត្តិធម៌ពីយន្តការផ្លូវការ (តុលាការ) | យន្តការដោះស្រាយវិវាទ ដែលមានលក្ខណៈ ងាយស្រួល អាចជួយកាត់បន្ថយភាពក្រីក្រ | ពង្រឹងយន្តការផ្លូវការ និងនៅមូលដ្ឋាន សម្រាប់ដោះស្រាយវិវាទ : នៅជិត ចំណាយតិច យល់ពីវប្បធម៌ និងងាយយល់នីតិវិធី |
| ២. រឿងក្តីនៅតុលាការ នៅសល់ច្រើនចាត់ការមិនទាន់ ហើយខ្វះខាតធនធាន | ឱកាសឱ្យមានការចូលរួមជាអតិបរិមាក្នុងការងារសង្គម | ចំណាយថវិកាកាន់តែច្រើនលើយន្តការដោះស្រាយវិវាទក្រៅតុលាការ ជាជាងចំណាយធនធានលើប្រព័ន្ធយុត្តិធម៌ផ្លូវការ។ |
| ៣. តុលាការមិនបានដោះស្រាយរាល់វិវាទ ដែលកើតមានក្នុងសង្គម។ នៅជនបទមានយន្តការដោះស្រាយវិវាទតាមប្រពៃណីសម្រាប់វិវាទកើតមាននៅមូលដ្ឋាន | មុខងារជំនាញ | តុលាការមិនគួររ៉ាប់រងដោះស្រាយរាល់វិវាទ ដែលកើតក្នុងសង្គមឡើយ ។ រឿងក្តីមួយចំនួនគួរតែអនុញ្ញាតឱ្យដោះស្រាយនៅក្រៅតុលាការ ដូចដែលមានជាក់ស្តែង ។ |
| ៤. តុលាការប្រើប្រាស់នីតិវិធីដោយធ្វើសេចក្តីសម្រេច (មានអ្នកចាញ់ និងឈ្នះ)។ | ដោះស្រាយដោយសន្តិវិធី (សន្តិភាពសង្គម) | ជាការមួយល្អប្រសើរ បើសិនជាវិវាទត្រូវបានដោះស្រាយដោយសន្តិវិធី។ យន្តការដោះស្រាយវិវាទក្រៅតុលាការគួរតែត្រូវបានពង្រឹង។ |
| ៥. មានវិវាទជាច្រើនដែលកើតមាននៅមូលដ្ឋាន | វិមជ្ឈការ និងប្រជាធិបតេយ្យ | មានដំណោះស្រាយនៅមូលដ្ឋាន សម្រាប់វិវាទដែលកើតមាននៅមូលដ្ឋាន។ បង្វែរធនធានសម្រាប់យន្តការដោះស្រាយវិវាទនៅមូលដ្ឋាន |

ការសិក្សាស្រាវជ្រាវនេះ បានគាំទ្រយល់ស្របចំពោះការសន្មតទាំងនេះ តែក៏មានចំណោទខ្លះចំពោះការសន្មតមួយចំនួនផងដែរ នៅពេលចាប់ផ្តើមធ្វើការសិក្សានេះ។ ការសិក្សានេះក៏មានបំណងបង្ហាញផងដែរ អំពីចំណុចខ្វះខាត ឬព្រំដែននៃយន្តការដោះស្រាយវិវាទផ្សេងៗ និងការបែងចែករបស់យន្តការទាំងនោះ ដែលជាក់ស្តែងកើតមានឡើងជារឿយៗ ដូចជាភាពខុសគ្នារវាងប្រព័ន្ធយុត្តិធម៌ផ្លូវការ និងមិនផ្លូវការជាដើម។ លទ្ធផលដែលទទួលបាន មានសុពលភាពសម្រាប់ការសិក្សានេះ ហើយអាចផ្តល់ជាមគ្គុទេសក៍សម្រាប់ គម្រោងស្រាវជ្រាវដទៃៗទៀតក្នុងវិស័យនេះ។ ខាងក្រោមនេះ ជាការទស្សនៈដោយសង្ខេបស្តីពីការសន្មតទាំងឡាយ ដែលជាមូលដ្ឋានសម្រាប់ការសិក្សានេះ រួមទាំងចំណោទនានា ដែលលើកឡើងតាមរយៈការរុករកឃើញជាលទ្ធផលរបស់យើង។

ការសន្មតជាក់ស្តែងទី១: ជនក្រីក្រ និងប្រជាពលរដ្ឋទន់ខ្សោយប្រឈមនឹងឧបសគ្គជាច្រើន ក្នុងការទទួលយកសេវាយុត្តិធម៌ពីប្រព័ន្ធតុលាការ រួមមានបញ្ហាខាងភូមិសាស្ត្រ សេដ្ឋកិច្ច និងខាងវប្បធម៌

មានការសិក្សាស្រាវជ្រាវជាច្រើន រួមទាំងការសិក្សានេះ បានគាំទ្រយល់ស្របអំពីឧបសគ្គ ដែលប្រជាពលរដ្ឋប្រឈមក្នុងការទទួលបានយុត្តិធម៌តាមផ្លូវតុលាការ ដោយសារថាតុលាការមានតែនៅថ្នាក់ខេត្ត-ក្រុងប៉ុណ្ណោះ តែប្រជាពលរដ្ឋប្រមាណជា ៨៤ % រស់នៅក្នុងភូមិ ឃុំ ជនបទដាច់ស្រយាលឆ្ងាយពីខេត្ត-ក្រុង[១]។ ប្រជាពលរដ្ឋត្រូវចំណាយថវិកាជាច្រើន ក្នុងការដោះស្រាយរឿងក្តីតាមផ្លូវតុលាការ ដោយត្រូវបង់លើតម្លៃដែលតម្រូវដោយច្បាប់ និងខុសច្បាប់ ចំណាយក្នុងការធ្វើដំណើរព្រមទាំងចំណាយសម្រាប់មេធាវី និងចំណាយផ្សេងៗទៀត។ ជាទូទៅនីតិវិធីប្រើពេលច្រើន និងខាតបង់ពេលវេលាច្រើនសម្រាប់គូភាគី ក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាលភាគច្រើន មិនស្គាល់ពីនីតិវិធីតុលាការ និងខ្វះការយល់ដឹងច្បាប់ ហើយមិនមានបទពិសោធន៍ ឬទំលាប់ជាមួយប្រព័ន្ធផ្លូវការទេ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋក្រីក្រពិបាកក្នុងការរកមេធាវី ឬជំនួយផ្នែកច្បាប់ ហើយពុំមានមេធាវីធ្វើការនៅតំបន់ជនបទដាច់ស្រយាលឡើយ។

ការសន្មតជាក់ស្តែងទី២: តុលាការមានរឿងក្តីច្រើនពេកចាត់ការមិនទាន់ ព្រមទាំងខ្វះខាតធនធានមនុស្ស និងធនធានសម្ភារៈ

តួលេខនៃចំនួនរឿងក្តីដែលនៅសល់ (មិនទាន់ដោះស្រាយ) ក្នុងមួយឆ្នាំៗ គឺប្រហាក់ប្រហែលទៅនឹងចំនួនរឿងក្តីដែលទទួល (រឿងក្តីប្តឹងចូលថ្មី) ក្នុងមួយឆ្នាំៗដែរ។ ដូច្នេះវាមានការពន្យារពេល ឬយឺតយ៉ាវរ៉ាំរ៉ៃ ក្នុងការដោះស្រាយរឿងក្តីនៅតុលាការ។ ហើយប្រហែលជានឹងនៅបន្តរក្សាស្ថានភាពនេះដូចនេះទៀត ព្រោះដំណើរការពង្រឹងស្ថាប័នសម្រាប់ប្រព័ន្ធយុត្តិធម៌ផ្លូវការ នឹងត្រូវការពេលវេលាជាច្រើនឆ្នាំទៀត ដើម្បីសម្រេចដល់គោលដៅ។

ការសន្មតជាក់ស្តែងទី៣: ក្នុងការអនុវត្តជាក់ស្តែង តុលាការដោះស្រាយរឿងក្តីតែចំនួនតូចប៉ុណ្ណោះ ក្នុងចំណោមករណីដែលអាចជារឿងក្តីបាន ហើយកើតមាននៅក្នុងសង្គម

មានវិវាទជាច្រើនលើសលុបត្រូវបានដោះស្រាយសម្រុះសម្រួលនៅក្រៅតុលាការ តាមរយៈយន្តការដោះស្រាយវិវាទផ្សេងៗ ជាពិសេសនៅជនបទដាច់ស្រយាល។ នេះគឺដោយសារតែហេតុផលដូចបានរៀបរាប់ក្នុងការសន្មតខាងលើ ហេតុផលប្រវត្តិសាស្ត្រ ព្រមទាំងចំនួន និងចរិតនៃវិវាទដែលបានកើតមាន។ មានប្រវត្តិដ៏យូរអង្វែងមកហើយទាក់ទងនឹងការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធយុត្តិធម៌ក្រៅផ្លូវការ ជាពិសេសនៅជនបទដាច់ស្រយាល។ ចាប់តាំងពីការបង្កើតប្រព័ន្ធយុត្តិធម៌តាមរបៀបលោកខាងលិច (តុលាការ) នៅក្នុងសម័យអាណាព្យាបាលរបស់បារាំងនៅសតវត្សរ៍ទី១៩មក គឺមានប្រព័ន្ធពីរដើរទៅលាយឡំនិងស្របជាមួយគ្នា។ ទីមួយគឺការអនុវត្តនៅតាមមូលដ្ឋាន ស្ថិតនៅក្រោមអាជ្ញាធរមូលដ្ឋាន ស្របតាមវប្បធម៌ និងទំនៀមទំលាប់នៅមូលដ្ឋាន ហើយទីពីរគឺការអនុវត្តន៍តាមប្រព័ន្ធច្បាប់ផ្លូវការរបស់រដ្ឋ ពោលគឺតុលាការស្ថិតនៅក្រោមអ្នកច្បាប់ដែលទទួលការបណ្តុះបណ្តាលតាមប្រព័ន្ធច្បាប់បារាំង។ ប្រព័ន្ធច្បាប់ផ្លូវការរបស់រដ្ឋ គ្របដណ្តប់តែនៅទីក្រុង និងទីប្រជុំជននៃប្រទេសតែប៉ុណ្ណោះ។ ក្រោយមកក្នុងរបបប៉ុលពត (ឆ្នាំ១៩៧៥-១៩៧៩) ប្រព័ន្ធតុលាការត្រូវបានបំផ្លាញទាំងស្រុង ហើយក៏ដូចគ្នានេះដែរចំពោះយន្តការដោះស្រាយទំនាស់នៅមូលដ្ឋាន។ បន្ទាប់ពីរបបនេះត្រូវបានបញ្ចប់ ប្រព័ន្ធច្បាប់មួយទៀតតាមបែបប្រទេសរុស្ស៊ី និងប្រទេសវៀតណាម ត្រូវបាននាំបញ្ចូលមកក្នុងស្រុកខ្មែរ ហើយបានធ្វើការកែប្រែប្រព័ន្ធយុត្តិធម៌ផ្លូវការ ប៉ុន្តែមិនបានបង្កើតតុលាការមួយឱ្យបានពេញលេញឡើយ។ ក្រោយពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (ឆ្នាំ១៩៩១) និងស្ថិតនៅក្នុង

---

១ ក្នុងចំណោមប្រជាពលរដ្ឋខ្មែរទាំងអស់ មានប្រជាពលរដ្ឋនៅជនបទដាច់ស្រយាលត្រូវបានគេប៉ាន់ប្រមាណថា មានប្រហែលជា ៨៤.៣% និងមាន ១៥.៧ % រស់នៅទីប្រជុំជន។ យោងតាមឯកសាររបស់វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)។ គេហទំព័រ: http://www.nis.gov.kh/SURVEYS/CDHS2000/AboutCDHS2001.htm (ចូលមើលគេហទំព័រនៅខែមេសា ឆ្នាំ២០០៥)។

សម័យអន្តរកាលក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ UNTAC (ជាពិសេសនៅក្នុងទស្សវត្សរ៍កន្លងទៅថ្មីៗនេះ) ប្រព័ន្ធតុលាការត្រូវបានគេយកចិត្តទុកដាក់ខិតខំបង្កើត និងកែលំអឡើងវិញ។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តី ជាក់ស្តែងនៅមានរឿងជាច្រើនទៀតត្រូវធ្វើដូចជា (១).កំណែទម្រង់ច្បាប់ ដើម្បីបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ (២).ការកសាងក្របខ័ណ្ឌស្ថាប័ន និង (៣).ការកសាងសមត្ថភាព។ តាមភូមិ ឃុំ នៅតំបន់ជនបទ ក៏មានដំណើរការកែលំអ និងកសាងឡើងវិញនូវយន្តការដោះស្រាយវិវាទផងដែរ។ ប្រជាពលរដ្ឋទៅរកអាជ្ញាធរមូលដ្ឋានឱ្យជួយដោះស្រាយវិវាទគ្រប់ប្រភេទដែលកើតមាន រួមទាំងវិវាទទាំងឡាយណាដែលតម្រូវឱ្យមានការសម្រេចពីតុលាការ ដូចជាករណីលែងលះ និងរឿងក្តីព្រហ្មទណ្ឌមួយចំនួនទៀត។ អាជ្ញាធរមូលដ្ឋានដោះស្រាយវិវាទជូនប្រជាពលរដ្ឋ ដោយយោងទៅតាមវប្បធម៌ និងទំនៀមទម្លាប់នៅមូលដ្ឋាន រួមទាំងអាស្រ័យលើតម្លៃ និងវិធានថ្មីៗ ផ្សេងៗទៀតផងដែរ។ ក្រៅពីអាជ្ញាធរមូលដ្ឋាន នគរបាលដើរតួយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ ដែលកើតមាននៅមូលដ្ឋាន។ មានរឿងក្តីព្រហ្មទណ្ឌជាច្រើនរួមទាំងករណីរដ្ឋប្បវេណីខ្លះ ដូចជាករណីបំណុលត្រូវបានដោះស្រាយដោយនគរបាលនៅថ្នាក់ឃុំ ស្រុក និងថ្នាក់ខេត្ត។ ដោយឡែកនៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ពួកគេមានប្រវត្តិជាប្រពៃណីយូរលង់ណាស់ មកហើយទាក់ទិននឹងការដោះស្រាយវិវាទដែលកើតមាននៅក្នុងសហគមន៍របស់ពួកគេ តាមរយៈចាស់ទុំនៅក្នុងសហគមន៍ និងស្របទៅតាមវិធានប្រពៃណីរបស់ពួកគេ តែក្នុងករណីខ្លះត្រូវបានដោះស្រាយតាមរយៈការសម្រុះសម្រួល និងតាមរយៈ យន្តការផ្លូវការដែលអាចវិនិច្ឆ័យសេចក្តីផងដែរ។

ការសន្មតជាការពិពណ៌នាទាំងនេះ ត្រូវបានអះអាងបញ្ជាក់បន្ថែមដោយការសិក្សាស្រាវជ្រាវនេះ។ តែទោះជាយ៉ាងនេះក្តី ក៏នៅមានការសន្មតដែលមានចែងជាបទបញ្ញត្តិផ្សេងទៀត តម្រូវឱ្យមានការបំភ្លឺបន្ថែមទៀត។

ការសន្មតទី៤: ភាពចាំបាច់ និងចំណាប់អារម្មណ៍ ក្នុងការពង្រីងយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR)

ការសន្មតមួយដែលមានចែងជាបញ្ញត្តិនោះគឺថា វាជាការមួយល្អប្រសើរក្នុងការដោះស្រាយវិវាទ ដោយសន្តិវិធីតាមរយៈយន្តការដោះស្រាយវិវាទដោយការសម្រុះសម្រួល ហើយការសន្មតនេះគឺជាហេតុផលយ៉ាងសំខាន់ គាំទ្រដល់គំនិតដែលថា មានការចាំបាច់ក្នុងការបង្កើត និងពង្រីយន្តការដោះស្រាយវិវាទក្រៅតុលាការ ADR។ យន្តការដោះស្រាយវិវាទក្រៅតុលាការត្រូវបានគេមើលឃើញថាជាយន្តការគោលមួយដ៏សំខាន់ ដើម្បីលើកស្ទួយសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនក្រីក្រ។ ទោះបីជាមានការពង្រឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ ដូចជាកែទម្រង់យន្តការដោះស្រាយវិវាទដែលចាំបាច់ក្តី តែវាមិនទាន់គ្រប់គ្រាន់នៅឡើយទេសម្រាប់ឆ្លើយតបចំពោះតម្រូវការយុត្តិធម៌ក្នុងសង្គមរបស់ជនក្រីក្រ។ ការសិក្សានេះ បានបញ្ជាក់យ៉ាងច្បាស់នូវហេតុផលជាច្រើន ដែលនាំទៅដល់សេចក្តីសន្និដ្ឋានមួយថា យន្តការដោះស្រាយវិវាទក្រៅតុលាការមិនមែនជា "យន្តការតែមួយគត់" ដែលអាចឆ្លើយតបចំពោះសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនក្រីក្រឡើយ។ ដោយហេតុថា យន្តការដោះស្រាយវិវាទក្រៅតុលាការ ជាយន្តការល្អបំផុតក្នុងការដោះស្រាយវិវាទតូចតាចរវាងអ្នកជិតខាង និងរវាងបងប្អូន ដូចនេះវាជាការមួយសំខាន់ណាស់ក្នុងការចង្អុលបង្ហាញថា វិវាទភាគច្រើនដែលអ្នកក្រីក្រប្រឈមគឺពាក់ព័ន្ធនឹងវិវាទដីធ្លីធំៗ និងហិង្សាខាងយេនឌ័រ ហើយនៅក្នុងបរិបទនេះ ប្រសិទ្ធិភាពនៃយន្តការដោះស្រាយវិវាទក្រៅតុលាការ គឺនៅមានកម្រិតនៅឡើយ។

មានការលំបាកយ៉ាងខ្លាំងក្នុងការដោះស្រាយវិវាទដីធ្លីធំៗរវាងអ្នកក្រីក្រ ឬជនជាតិដើមភាគតិច ជាមួយនឹងភាគីអ្នកមានអំណាច (អ្នកមានទ្រព្យសម្បត្តិ មន្ត្រីមានឋានន្តរស័ក្តខ្ពស់ យោធា ក្រុមហ៊ុន សម្បទានិក) តាមរយៈយន្តការដោះស្រាយវិវាទក្រៅតុលាការ។ យន្តការដោះស្រាយវិវាទក្រៅតុលាការ គឺអាស្រ័យលើការចរចាររវាងគូភាគីដោយស្មើភាពគ្នា និងមិនចាំបាច់ពិចារណាអំពីសិទ្ធិដែលពាក់ព័ន្ធ។ បើសិនជាភាគីអ្នកមានអំណាចជាង មិនទទួលស្គាល់សិទ្ធិរបស់ភាគីខ្សោយជាងនោះ ប្រហែលជាមិនអាចឈានដល់ការព្រមព្រៀងមួយដែលយុត្តិធម៌ឡើយ។ យន្តការដោះស្រាយវិវាទដែលមានស្រាប់ ដូចជាគណៈកម្មការ

សុរិយោដី និងអាជ្ញាធរមូលដ្ឋាន មិនមានលទ្ធភាពសម្រុះសម្រួលដោយយុត្តិធម៌ឡើយសម្រាប់វិវាទ ដែលភាគីម្ខាងជាអ្នកមានអំណាចជាងភាគីម្ខាងទៀត ហើយទុកឱ្យបញ្ហាសង្គមទាំងនេះបន្តកើតឡើងដោយគ្មានដំណោះស្រាយ។ អតុល្យភាពក្នុងការចរចាររវាងភាគីវិវាទ គឺជាបញ្ហាសង្គម និងនយោបាយដ៏ចម្បងនៅព្រះរាជាណាចក្រកម្ពុជា ហើយនេះជាសក្តានុពលនៃការបន្តមានហិង្សា និងវិវាទនៅក្នុងសង្គម។

យន្តការដោះស្រាយវិវាទក្រៅតុលាការ ហាក់ដូចជាមិនមានប្រសិទ្ធិភាពទេ ក្នុងការឆ្លើយតបទៅនឹងតម្រូវការយុត្តិធម៌ក្នុងសង្គម ដែលទាក់ទិនទឹងហិង្សាខាងយេនឌ័រ និងសិទ្ធិកុមារ ជាពិសេសក្នុងករណីដែលបុរសមិនគោរពសិទ្ធិស្ត្រី និងសិទ្ធិកុមារ ឬនៅបន្តប្រព្រឹត្តហិង្សា។ ដូច្នេះ ដរាបណាអាជ្ញាធរមូលដ្ឋាន គ្រាន់តែដើរតួជាអ្នកសម្រុះសម្រួល តែពុំមានសិទ្ធិសម្រេច ឬបង្ខំឱ្យភាគីគោរពសិទ្ធិទេនោះ ការគោរពសិទ្ធិកុមារ និងសិទ្ធិស្ត្រីមិនអាចធានាបានឡើយ ព្រោះថាការគោរពសិទ្ធិទាំងនេះ អាស្រ័យទាំងស្រុងលើឆន្ទៈរបស់បុរសៗ ក្នុងការបំពេញមុខនាទីរបស់ខ្លួន។ អាជ្ញាធរមូលដ្ឋាន ដោះស្រាយវិវាទភាគច្រើនដោយផ្អែកលើការធ្វើសម្បទានរបស់ភាគី ជាជាងការធានាដល់ការគោរពសិទ្ធិស្ត្រី និងសិទ្ធិកុមារ។ ទោះជាយ៉ាងនេះក្តី គួរកត់សំគាល់ថាដរាបណាមានភាពមិនស្មើគ្នារវាងបុរស និងស្ត្រី នោះវាអាចឈានដល់លទ្ធផលមួយដែលមិនមានភាពយុត្តិធម៌ ក្រោមប្រព័ន្ធយុត្តិធម៌ក្រៅផ្លូវការ ក៏ដូចជាយន្តការដោះស្រាយវិវាទក្រៅតុលាការ។ ចំណុចខ្សោយរបស់យន្តការដោះស្រាយវិវាទក្រៅតុលាការគឺត្រង់ថា ចំពោះវិវាទដែលទាក់ទងនឹងការការពារសិទ្ធិរបស់ភាគី យន្តការនេះខ្វះសមត្ថភាពដើម្បីបង្ខំឱ្យភាគីគោរពសិទ្ធិបើសិនជាភាគីមួយមិនព្រមគោរព។ ក្នុងបរិបទនេះ អ្វីដែលជាតម្រូវការចាំបាច់នោះ គឺត្រូវមានអាជ្ញាធរស្របច្បាប់មួយដែលមានសមត្ថកិច្ច និងយុត្តាធិការក្នុងការសម្រេច និងបង្ខំឱ្យភាគីគោរពសិទ្ធិ។ ដូចគ្នានេះផងដែរ គួរអនុវត្តចំពោះករណីមួយចំនួនដែលតម្រូវឱ្យមានការសម្រេចរបស់តុលាការ ដូចជាករណីលែងលះ និងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរជាដើម។ នៅពេល បច្ចុប្បន្ននេះ អាជ្ញាធរមូលដ្ឋានកំពុងដោះស្រាយរាល់បញ្ហាទាំងនេះ ទោះបីពុំមានសមត្ថកិច្ចស្របច្បាប់ក៏ដោយ។ តាមច្បាប់ យន្តការដោះស្រាយវិវាទក្រៅតុលាការ មិនមានអំណាចស្របច្បាប់ ក្នុងការផ្តល់ការលែងលះ ឬដោះស្រាយវិវាទទាក់ទិននឹងរឿងក្តីព្រហ្មទណ្ឌឡើយ។

សមត្ថភាពរបស់យន្តការដោះស្រាយវិវាទក្រៅតុលាការក៏មានកម្រិតផងដែរ ក្នុងការឆ្លើយតបចំពោះតម្រូវការយុត្តិធម៌របស់សង្គម ដូចជាការរំលោភសិទ្ធិ (ការឃុំខ្លួនខុសច្បាប់ ការធ្វើទារុណកម្ម និងប្រព្រឹត្តិមិនសមរម្យចំពោះអ្នកជាប់ពន្ធនាគារ) និងការរំលោភអំណាចដោយមន្ត្រីសាធារណៈ (ការទាមទារឱ្យបង់ថ្លៃដោយខុសច្បាប់ក្នុងការផ្តល់សេវាសាធារណៈ)។ កត្តាទាំងនេះទាមទារឱ្យមានការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាចដ៏មានប្រសិទ្ធិភាពមួយ ដើម្បីត្រួតពិនិត្យការរំលោភអំណាច។ ជារួម ទោះបីជាចាំបាច់ត្រូវពង្រឹងយន្តការដោះស្រាយវិវាទ ដើម្បីដោះស្រាយវិវាទមួយចំនួន ប៉ុន្តែយន្តការដោះស្រាយវិវាទក្រៅតុលាការនេះ អាចជួយដោះស្រាយ និងឆ្លើយតបបានតែមួយផ្នែកណាមួយនៃតម្រូវការយុត្តិធម៌នៅក្នុងសង្គមរបស់អ្នកក្រីក្រប៉ុណ្ណោះ។

ការសន្មតទី៥: ត្រូវមានយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន សម្រាប់ដោះស្រាយរាល់វិវាទដែលកើតមាននៅក្នុងមូលដ្ឋាន

ការសន្មតទី ៥ គឺជាការសន្មតទុកជាមុនថាសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនក្រីក្រ អាចត្រូវបានកែលំអ តាមរយៈការពង្រឹងសមត្ថភាពមូលដ្ឋានដើម្បីដោះស្រាយវិវាទ។ ជាគោលការណ៍ ការសន្មតនេះជាការត្រឹមត្រូវ។ ជាទូទៅ ជាការល្អបំផុតបើវិវាទដែលកើតមាននៅមូលដ្ឋាន ត្រូវបានគេដោះស្រាយនៅមូលដ្ឋានផ្ទាល់។ ការកសាងសមត្ថភាពដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាន គួរតែជាផ្នែកមួយនៃដំណើរការធ្វើវិមជ្ឈការ។ ពិតណាស់ថា មិនមែនរាល់វិវាទ ឬបញ្ហាទាំងអស់ដែលប៉ះពាល់ដល់អ្នកក្រីក្រ សុទ្ធតែមានប្រភពពីប្រជាពលរដ្ឋនៅមូលដ្ឋាននោះទេ ដូច្នេះ ការរកដំណោះស្រាយចំពោះវិវាទ ឬបញ្ហាទាំងនោះត្រូវតែពិចារណាអំពីចរិតលក្ខណៈនៃវិវាទ ដែលមិនមែនមានប្រភពមកពីអ្នកនៅមូលដ្ឋានផ្ទាល់។ ជាឧទាហរណ៍ ការធ្វើសម្បទានដី

និងធនធានធម្មជាតិ ដែលនាំឱ្យមានការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំ ហើយប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់រយគ្រួសារ និងច្រើនភូមិ។ ក្នុងករណីនេះ ដំណោះស្រាយគួរតែមិនមែននៅថ្នាក់មូលដ្ឋានទេ តែត្រូវដោះស្រាយនៅថ្នាក់ជាតិវិញ។ ដូចនេះ បើគ្រាន់តែពង្រឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ដើម្បីដោះស្រាយវិវាទ ប្រហែលជាមិនអាចឆ្លើយតបចំពោះគ្រប់តម្រូវការយុត្តិធម៌ក្នុងសង្គមឡើយ។

កត្តាមួយផ្សេងទៀតដ៏សំខាន់គឺថា កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ គឺត្រូវតែផ្តល់អំណាចយុត្តាធិការ ចំពោះអាជ្ញាធរដោះស្រាយវិវាទនៅមូលដ្ឋានមួយចំនួន ដើម្បីដោះស្រាយវិវាទដែលកើតមាននៅមូលដ្ឋាន។ រាល់វិវាទ ឬបញ្ហាដែលកើតមាននៅមូលដ្ឋាន មិនអាចត្រូវបានដោះស្រាយដោយជោគជ័យ តាមរយៈយន្តការដោះស្រាយវិវាទក្រៅតុលាការតែមួយប៉ុណ្ណោះទេ ពីព្រោះមិនមែន គ្រប់វិវាទទាំងអស់ត្រូវបានស្រុះស្រួលដោយស្ម័គ្រចិត្តតាមរយៈការចរចារ ឬការសម្រុះសម្រួលនោះឡើយ។ ការផ្តល់អំណាច យុត្តាធិការដល់ថ្នាក់មូលដ្ឋាន ឬថ្នាក់ស្រុក គឺជាការចាំបាច់ដើម្បីទទួលស្គាល់ និងអនុវត្តសិទ្ធិកុមារ និងសិទ្ធិស្ត្រីឱ្យបាន ក៏ដូចជាដើម្បីការពារនិងទប់ស្កាត់បទល្មើសព្រហ្មទណ្ឌនៅមូលដ្ឋាន និងត្រួតពិនិត្យការរំលោភអំណាចនៅមូលដ្ឋានផងដែរ។ ដូចនេះ ការពង្រឹងសមត្ថភាពមូលដ្ឋានដើម្បីដោះស្រាយវិវាទ គឺមានន័យថាជាការធ្វើវិមជ្ឈការ និងវិសហមជ្ឈការអំណាចដល់ថ្នាក់មូលដ្ឋាន និងស្រុក។

ការសន្មតផ្សេងៗទៀតដែលតម្រូវឱ្យមានការបញ្ជាក់បន្ថែម គឺគំនិតដែលថា បន្ទុករបស់តុលាការ ក្នុងការដោះស្រាយវិវាទនឹងត្រូវកាត់បន្ថយជាស្វ័យប្រវត្តិ បើសិនជាយន្តការដោះស្រាយវិវាទក្រៅតុលាការ ត្រូវបានគេពង្រឹងនោះ។ មានប្រភេទរឿងក្តីមួយចំនួន ដែលច្បាប់តម្រូវឱ្យស្ថិតក្រោមសមត្ថកិច្ចតុលាការ និងត្រូវតែដោះស្រាយតាមផ្លូវតុលាការ ដូចជាករណី លែងលះ និងបញ្ហាព្រហ្មទណ្ឌនានា។ រឿងក្តីលែងលះមានប្រហែលជា ៤០% នៃរឿងក្តីរដ្ឋប្បវេណី ដែលប្តឹងទៅតុលាការ និងរឿងក្តីព្រហ្មទណ្ឌមានប្រមាណជាង ៥០% នៃរឿងក្តីទាំងអស់។ ទោះជាយ៉ាងនេះក្តី វាជាការមួយមានតម្លៃណាស់ ក្នុងការបញ្ជាក់ឡើងវិញថា នៅតុលាការមានរឿងក្តីច្រើនលើសលុប ហើយមិនអាចឆ្លើយតបគ្រប់គ្រាន់ចំពោះតម្រូវការយុត្តិធម៌នាពេលបច្ចុប្បន្នបាន ទាំងក្នុងផ្នែកព្រហ្មទណ្ឌ និងផ្នែកខាងវិវាទគ្រួសារ។ ជាលទ្ធផល មានរឿងក្តីជាច្រើនករណី ទាំងផ្នែកព្រហ្មទណ្ឌ និងគ្រួសារត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន និងនគរបាល ទោះបីដឹងថាពួកគេពុំមានសមត្ថកិច្ចតាមផ្លូវច្បាប់ដើម្បីដោះស្រាយវិវាទ ឬបញ្ហាទាំងនេះក៏ដោយ។

បន្ថែមលើសនេះទៅទៀត តុលាការមិនអាចពិនិត្យឡើងវិញ នូវការអនុវត្តនៃអំណាចសាធារណៈ ដែលមានការរំលោភអំណាចឡើយ។ រហូតមកដល់ឆ្នាំ២០០៣ ពុំទាន់មានរឿងក្តីណាមួយពាក់ព័ន្ធនឹងករណីអំពើពុករលួយត្រូវបានគេប្តឹងឡើងទៅតុលាការនៅឡើយទេ ទោះបីជាមានអំពើពុករលួយយ៉ាងទូលំទូលាយ ក្នុងការផ្តល់សេវាសាធារណៈ (វិស័យអប់រំ សុខាភិបាល និងយុត្តិធម៌) ហើយនិងខ្វះតម្លាភាពក្នុងការគ្រប់គ្រងធនធាន ឬទ្រព្យសាធារណៈ (សម្បទាន ការធ្វើលទ្ធកម្មសាធារណៈ និងគម្រោងអភិវឌ្ឍន៍នានា។ល។)[២]។ ស្រដៀងគ្នានេះដែរ ត្រូវបានគេមើលឃើញថា តុលាការពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យការរំលោភនីតិវិធីច្បាប់ ដែលជាហេតុនាំឱ្យមានការប្រព្រឹត្តិមិនសមរម្យចំពោះអ្នកជាប់ពន្ធនាគារ និងការរំលោភលើនីតិវិធីច្បាប់តាមរូបភាពផ្សេងៗទៀត។ មានរឿងក្តីច្រើនលើសលុបនៅតុលាការ តែក្រៅពីរឿងក្តីដ៏ច្រើនលើសលុបទាំងនេះ នៅមានបញ្ហាបន្ទាន់ៗជាច្រើនទៀតដែលទាមទារឱ្យមានអន្តរាគមន៍ពីតុលាការ។ ការនេះឆ្លុះបញ្ចាំងឱ្យ

---

២ អ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលជួបសម្ភាសន៍ទាំងឡាយបានលើកឡើងថា អំពើពុករលួយមានសភាពយ៉ាងទូលំទូលាយនិងទូទៅ នៅក្នុងរដ្ឋបាលសាធារណៈរបស់ប្រទេសកម្ពុជា។ កត្តានេះត្រូវបានរកឃើញនិងបញ្ជាក់ដោយការធ្វើស្ទង់មតិ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមនៅឆ្នាំ១៩៩៨ និងឆ្នាំ ២០០៥។

ឃើញថា ប្រព័ន្ធយុត្តិធម៌ផ្លូវការ នៅមិនទាន់តម្រង់ការខិតខំរបស់ខ្លួនចំពោះការការពារសិទ្ធិ និងត្រួតពិនិត្យការរំលោភអំណាច មុខងារ ដែលយន្តការដោះស្រាយវិវាទក្រៅតុលាការ មិនអាចធ្វើបាននៅឡើយទេ។

ដើម្បីកាត់បន្ថយបន្ទុករបស់តុលាការ និងបង្វែរករណីមួយចំនួនឱ្យទៅដោះស្រាយនៅយន្តការដោះស្រាយវិវាទក្រៅតុលាការ និងនៅមូលដ្ឋាននោះ តុលាការ (និងប្រព័ន្ធយុត្តិធម៌ផ្លូវការទាំងអស់) ចាំបាច់ត្រូវតែផ្តល់អាទិភាពចំពោះប្រភេទនៃរឿងក្តីទាំងនោះ (ការការពារសិទ្ធិមនុស្ស ការត្រួតពិនិត្យការរំលោភអំណាច និងបញ្ហាផ្សេងៗទៀតដែលតម្រូវឱ្យត្រូវតែដោះស្រាយតាមផ្លូវតុលាការ) ពោលគឺករណីដែលយន្តការដោះស្រាយវិវាទក្រៅតុលាការ មិនអាចដោះស្រាយបាន ។ ដោយហេតុដូចគ្នានេះដែរ យន្តការដោះស្រាយវិវាទក្រៅតុលាការត្រូវតែពង្រឹង និងមានក្របខ័ណ្ឌច្បាប់សមស្រប ក្នុងការអនុវត្ត និងប្រតិបត្តិ ដើម្បីឱ្យរឿងក្តីរដ្ឋប្បវេណីកាន់តែច្រើនត្រូវបានដោះស្រាយដោយមិនចាំបាច់ឡើងទៅតុលាការ។ ប្រព័ន្ធយុត្តិធម៌មូលដ្ឋាន គួរតែមានសមត្ថកិច្ចស្របច្បាប់ក្នុងការអនុវត្តប្រពៃណី ទំនៀមទំលាប់របស់មូលដ្ឋាន ព្រមទាំងមានអំណាចយុត្តាធិការដើម្បីដោះស្រាយវិវាទ និងទទួលស្គាល់សិទ្ធិក្នុងករណីទាំងឡាយណា ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍តាមប្រពៃណី អំពើហិង្សាក្នុងគ្រួសារ និងបទល្មើសតូចតាចនានា។ វាក៏ចាំបាច់ផងដែរ ក្នុងការទទួលស្គាល់ និងពង្រឹងច្បាប់ទំនៀមទំលាប់របស់សហគមន៍ជនជាតិដើមភាគតិច និងអាជ្ញាធររបស់ពួកគេ ក្នុងការដោះស្រាយវិវាទដែលកើតមាននៅក្នុង និងរវាងសហគមន៍ជនជាតិដើមភាគតិច ឬវិវាទដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ទោះនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ឬនៅក្រៅសហគមន៍ក្តី ដែលពួកគេត្រូវបានគេចោទថាប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីណាមួយនោះ។

កន្លងមក ស្ទើរតែរាល់ការខិតខំក្នុងការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺផ្តោតសំខាន់លើតែប្រព័ន្ធផ្លូវការតែប៉ុណ្ណោះ។ ឥឡូវនេះ អ្នកពាក់ព័ន្ធមួយចំនួន បានស្នើឡើងឱ្យបង្វែរធនធានទៅបង្កើត និងពង្រឹង "យន្តការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅតុលាការ ឬក្រៅផ្លូវការ" វិញ ដើម្បីធានាឱ្យបាននូវយុត្តិធម៌សម្រាប់ទាំងអស់គ្នា ជាពិសេសសម្រាប់អ្នកក្រីក្រ។ នេះគឺជាភាពអល់អែកមួយមិនត្រឹមត្រូវឡើយ។ ចក្ខុវិស័យភាពលើពហុសេវាកម្មយុត្តិធម៌នៃសេវាកម្មយុត្តិធម៌ទាំងអស់អាចមានប្រយោជន៍ និងដោះស្រាយនូវភាពប្រទាញប្រទង់រវាងទស្សនៈនៃប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ។ គោលបំណងនៃការធ្វើកំណែទម្រង់តាមបែបពហុនិយមនេះ ដោះស្រាយវិវាទ គឺសំដៅលើការទទួលស្គាល់នៃយន្តការទាំងនោះ។ បើសិនជាយន្តការ (តុលាការ យន្តការដោះស្រាយវិវាទក្រៅតុលាការ និងយន្តការរបស់ជនជាតិដើមភាគតិច) ត្រូវបានទទួលស្គាល់ដោយច្បាប់ និងត្រូវបានសម្របសម្រួលរវាងគ្នា ដោយគោរពតាមគោលការណ៍ប្រជាធិបតេយ្យនោះ យន្តការទាំងនោះអាចឆ្លើយតបកាន់តែប្រសើរចំពោះតម្រូវការយុត្តិធម៌ក្នុងសង្គម។ បញ្ហាសំខាន់ គឺនៅត្រង់ការបំពេញមុខងាររបស់គេ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់សង្គម។ ធ្វើបែបនេះ តុលាការអាចមានមុខងារកាន់តែជាក់លាក់ ទាក់ទិននឹងការដោះស្រាយវិវាទតាមប្រភេទ ការពារសិទ្ធិមនុស្ស និងត្រួតពិនិត្យការរំលោភអំណាច។ យន្តការដោះស្រាយវិវាទក្រៅតុលាការ គួរដោះស្រាយរាល់វិវាទទាំងឡាយណា ដែលមិនពាក់ព័ន្ធដល់ការធានា និងផ្តល់សិទ្ធិជូនដល់ភាគី។ យុត្តិធម៌មូលដ្ឋានអាចមានមុខងារទាំងពីរពោលគឺ ជាយន្តការដោះស្រាយវិវាទក្រៅតុលាការ និងអាចធ្វើសេចក្តីសម្រេចសម្រាប់ភាគីនៅពេលចាំបាច់ តែត្រូវពិចារណាលើទំនៀមទំលាប់ប្រពៃណីនៅមូលដ្ឋាន។ ច្បាប់ជនជាតិដើមភាគតិច គួរត្រូវបានទទួលស្គាល់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដោយយកចិត្តទុកដាក់លើមុខងារសម្រេចសេចក្តី យោងទៅតាមវិធានអាជ្ញាធរ និងនីតិវិធីដោះស្រាយរបស់ពួកគេ។ យន្តការទាំងអស់នេះ គួរតែមានគណនេយ្យភាពស្របច្បាប់ និងមានទំនុកចិត្តពីប្រជាពលរដ្ឋ ព្រមទាំងមាននីតិវិធីសមស្របក្នុងការត្រួតពិនិត្យ ការរំលោភអំណាច និងរបៀបដោះស្រាយវិវាទខាងសមត្ថកិច្ចរវាងយន្តការទាំងនេះ។

បន្ទាប់ពីមានការបញ្ជាក់អំពីបញ្ហាទាំងនេះហើយ ការសិក្សានេះព្យាយាមលើកឡើងនូវចំណោទជាក់លាក់មួយចំនួន ដូចជា ថាតើយន្តការដោះស្រាយវិវាទក្រៅតុលាការនៅថ្នាក់ណាដែលត្រូវពង្រឹង និងពង្រឹងត្រឹមកម្រិតណា? តើចាំបាច់ត្រូវផ្តល់អំណាចយុត្តាធិការត្រឹមថ្នាក់ណា ដើម្បីឱ្យមានដំណោះស្រាយវិវាទនៅមូលដ្ឋានមួយប្រកបដោយចីរភាព និងមានន័យអាចទទួលយកបាន? តើត្រូវធ្វើដូចម្តេចដើម្បីឱ្យច្បាប់ជនជាតិដើមភាគតិច និងយន្តការដោះស្រាយវិវាទរបស់សហគមន៍ជនជាតិដើមភាគតិច អាចនៅទន្ទឹមគ្នាជាមួយនឹងប្រព័ន្ធយុត្តិធម៌ផ្សេងៗទៀតនៅក្នុងប្រទេស? តើត្រូវបែងចែកមុខងារដោះស្រាយវិវាទក្នុងចំណោមយន្តការដោះស្រាយវិវាទផ្សេងៗ ដោយរបៀបណា? តើគួរបង្កើតយន្តការដោះស្រាយវិវាទក្រៅតុលាការប្រភេទណាខ្លះ ដើម្បីដោះស្រាយរឿងក្តីព្រហ្មទណ្ឌ? តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីត្រួតពិនិត្យតម្លាភាព ក្នុងការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែប្រសើរឡើង? តើគួរផ្តល់អំណាចដល់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិចដោយរបៀបណា ដើម្បីឱ្យពួកគេអាចចូលរួមដំណើរការកំណែទម្រង់លើសិទ្ធិទទួលបានយុត្តិធម៌?

របាយការណ៍សិក្សាស្រាវជ្រាវនេះ មានបួនជំពូក។ ជំពូកទី១ ពន្យល់អំពីក្របខ័ណ្ឌទស្សនាទាន និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ។ ជំពូកទី២ វិភាគអំពីតម្រូវការយុត្តិធម៌នៅក្នុងសង្គមជំពូក។ ទី៣ ធ្វើការវាយតម្លៃចំពោះការផ្តល់សេវាកម្មយុត្តិធម៌។ ជំពូកទី៤ ជាសេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា ដែលទទួលបានពីការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ជាអនុសាសន៍ចំពោះការកែលំអគោលនយោបាយ ដោយគោរពសិទ្ធិទទួលបានយុត្តិធម៌ ផ្តោតសំខាន់លើយុត្តិធម៌មូលដ្ឋាន ។